# ការណែនាំមាតាបិតាអំពីការចាក់ថ្នាំបង្ការរោគ
# តម្រូវឱ្យមានសម្រាប់ការចូលរៀននៅសាលា

ចាប់ផ្តើមពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2019

## សិស្សដែលអនុញ្ញាតឱ្យចូលរៀនថ្នាក់ TK/K-12 ត្រូវការ៖

- ខាន់ស្លាក់ (Diphtheria), តេតាណុស (Tetanus), និងក្អកមាន់ (Pertussis) (DTaP, DTP, Tdap, ឬ Td) — 5 ដូស
  (4 ដូស អូខេ បើបានចាក់មួយហើយ នៅថ្ងៃឬក្រោយថ្ងៃកំណើតទី 4 ។
  (3 ដូស អូខេ បើបានចាក់មួយហើយ នៅថ្ងៃឬក្រោយថ្ងៃកំណើតទី 7 ។
  សម្រាប់សិស្សថ្នាក់ទី 7 ដល់ 12 ការចាក់វ៉ាក់សាំងដែលមានផ្ទុកថ្នាំបង្ការក្អកមាន់យ៉ាងតិច 1 ដូស តម្រូវឱ្យមាននៅថ្ងៃឬក្រោយថ្ងៃកំណើតទី 7 ។

- ប៉ូលីយោ Polio (OPV ឬ IPV) — 4 ដូស
  (3 ដូស អូខេ បើបានចាក់មួយហើយនៅថ្ងៃឬក្រោយថ្ងៃកំណើតទី 4 )

- រលាកថ្លើមប្រភេទបេ Hepatitis B — 3 ដូស
  (មិនតម្រូវឱ្យមានសម្រាប់សិស្សចូលរៀនថ្នាក់ទី 7)

- កញ្ជ្រឹល (Measles), ក្រឡទែន (Mumps), និងរោគកញ្ជ្រឹលស្រាល (Rubella) (MMR) — 2 ដូស
  (វ៉ាក់សាំងទាំងពីរត្រូវចាក់នៅថ្ងៃ ឬក្រោយថ្ងៃកំណើតទី 1)

- Varicella (អុតស្វាយ Chickenpox) — 2 ដូស

តម្រូវឱ្យមានការចាក់ថ្នាំបង្ការរោគទាំងនេះ ត្រូវអនុវត្តចំពោះការអនុញ្ញាតឱ្យចូលរៀនសិស្សថ្មី និងការផ្ទេរសាលារៀនគ្រប់កម្រិតថ្នាក់ទាំងអស់ ដែលរួមមានមត្តេយ្យសាលាបណ្តោះអាសន្ន។

## សិស្សចាប់ផ្តើមចូលរៀនថ្នាក់ទី 7 ត្រូវការ៖

- តេតាណុស (Tetanus), ខាន់ស្លាក់ (Diphtheria), ក្អកមាន់ (Pertussis) (Tdap) —1 ដូស
  (តាមធម្មតាការចាក់ថ្នាំបង្ការរោគក្អកមាន់ ត្រូវចាក់ថ្នាំចាប់ពីអាយុ 11 ឆ្នាំឡើង)

- Varicella (អុតស្វាយ Chickenpox) — 2 ដូស
  (តាមធម្មតាត្រូវចាក់ថ្នាំនៅអាយុ 12 ខែ និង 4-6 ឆ្នាំ)

លើសពីនេះតម្រូវឱ្យមានការចាក់ថ្នាំបង្ការរោគនៅថ្នាក់ TK/K-12 ត្រូវអនុវត្តចំពោះសិស្សថ្នាក់ទី 7 ដែល៖

- កាលពីមុនមានការលើកលែងតាមជំនឿផ្ទាល់ខ្លួនត្រឹមត្រូវ ដែលបានដាក់ឯកសារមុនឆ្នាំ 2016 នៅពេលចូលរៀននៅចន្លោះថ្នាក់ TK/សាលាមត្តេយ្យ និងថ្នាក់ទី 6
- មានការអនុញ្ញាតឱ្យចូលរៀនសិស្សថ្មី

## កំណត់ត្រា៖

សាលារៀនរដ្ឋកាលីហ្វ័រញ៉ា California
តម្រូវឱ្យមានការពិនិត្យមើលកំណត់ត្រាចាក់ថ្នាំបង្ការរោគសម្រាប់ការអនុញ្ញាតឱ្យចូលរៀនសិស្សថ្មីទាំងអស់នៅថ្នាក់ TK/សាលាមត្តេយ្យ រហូតដល់ថ្នាក់ទី 12 និងសិស្សទាំងអស់ដែលឡើងថ្នាក់ទី 7 មុនការចូលរៀន។
មាតាបិតាត្រូវតែបង្ហាញកំណត់ត្រាចាក់ថ្នាំបង្ការរោគកូនរបស់ពួកគេជាឯកសារបញ្ជាក់អំពីការចាក់ថ្នាំបង្ការរោគ។